**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៣២៧ សហវ.អសក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០១៤

គោរពជូន

-ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន

-ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

-ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

-ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា

-ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

-ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

-ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

-ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន

**កម្មវត្ថុ:** ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៤

**យោង:**
- ព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ព្រះរាជក្រមលេខ នស /រកម/ ១២១២/០១០ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- អនុក្រឹត្យលេខ ៤៨៨ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៤០ / អនក្រ / បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- ប្រកាសលេខ ១៥៤៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ៨០៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារក្រមសីលធម៌សម្រាប់សវនករផ្ទៃក្នុង និងស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង
- ប្រកាសលេខ ២៩៥ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារបច្ចុប្បន្នកម្មនៃគោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុង
- លិខិតលេខ សហវ.អសក ចុះថ្ងៃទី ខែ ឆ្នាំ ២០១៤ ស្តីពីផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ២០១៤-២០១៦

- សារាចរណែនាំលេខ ១២ សរណន ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ដើម្បីបន្តរក្សានិរន្តរភាពជោគជ័យនៃការងារកំណែទម្រង់របស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់លើវិស័យហិរញ្ញវត្ថុសាធារណៈនិយាយជារួម និងនិយាយដោយឡែក ការកសាងលក្ខណៈសម្បត្តិសម្រាប់បោះជំហានចូលដំណាក់កាលទី ៣ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានណែនាំឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៤ ដោយផ្តោតជាសំខាន់ទៅលើការធានាភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យនៃកិច្ចដំណើរការថ្មីៗ(Business Process) ដែលជាសមិទ្ធកម្មនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មកទល់ពេលបច្ចុប្បន្ននេះ ពិសេសការឈានទៅគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យាលើមូលដ្ឋានរតនាគារ (FMIS Treasury Centric Module) ។ ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៤ ក៏ត្រូវបានរក្សាសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ២០១៤-២០១៦ ផងដែរ ។

ទន្ទឹមនឹងនេះ ការរៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៤ ត្រូវបានណែនាំឲ្យគោរពតាមអភិក្រមនិងនីតិវិធីស្តង់ដាសវនកម្មឧត្តមានុវត្ត ធានាបាននូវភាពជាក់ស្តែងអាចអនុវត្តបាន និងសមស្របជាមួយពេលវេលា និងលទ្ធភាពរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងផងដែរ ។

ជាលទ្ធផល ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៤ នេះបានគ្របដណ្តប់ទៅលើកិច្ចដំណើរការសំខាន់ៗដែលមានហានិភ័យរបស់អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពថ្នាក់មូលដ្ឋាននៅតាមរាជធានី-ខេត្ត តាមការវាយតម្លៃរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (សូមពិនិត្យផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៤ ដូចជូនភ្ជាប់)។

ក្រៅពីគោលបំណងជួយពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពថ្នាក់មូលដ្ឋាន ការគោរពតាមផែនការនិងអនុលោមភាពនៃនីតិវិធី និងបទដ្ឋានច្បាប់ពិសេសវិន័យថវិកា ១១ ចំណុច ផែនការសវនកម្មផ្ទៃក្នុង ២០១៤ ក៏បានផ្តោតការយកចិត្តទុកដាក់លើបញ្ហាអភិបាលកិច្ចល្អ ពិសេសប្រព័ន្ធទ្រទ្រង់គុណភាពសេវាសាធារណៈ សមត្ថភាពជំនាញ ក្រមសីលធម៌របស់មន្ត្រីរាជការ និងការទប់ស្កាត់អំពើកេងបន្លំផងដែរ។

ដូច្នេះ ដើម្បីឲ្យការអនុវត្តផែនការសវនកម្មផ្ទៃក្នុង ២០១៤ ដែលមានវិសាលភាពនិងគោលបំណងខាងលើសម្រេចបានផលល្អ ខ្ញុំសូមឯកឧត្តមផ្តល់ការយកចិត្តទុកដាក់ និងកិច្ចសហការជិតស្និទ្ធជូនដល់សវនករ ។ ការតាមដានទៅលើការកែលម្អតាមអនុសាសន៍នឹងត្រូវធ្វើក្នុងរយៈពេល ៦ ខែក្រោយសវនកម្មបានបញ្ចប់ ។

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវចុះធ្វើសវនកម្ម ទៅតាមផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៤ នេះ និងក្នុងករណីចាំបាច់លើមូលដ្ឋានបណ្តឹង សំណូមពររបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមការណែនាំដោយឡែករបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តមជ្រាប និងផ្តល់កិច្ចសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុងឆ្នាំ ២០១៤ នេះឱ្យបានសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ។៤/

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

*ចំលងជូន:*

- អាជ្ញាធរសវនកម្មជាតិ
- ឯកសារ-កាលប្បវត្តិ